ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០១៩

## សេចក្តីផ្តើម

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារតាមតួនាទី ភារកិច្ច យ៉ាងសកម្មលើមុខងារស្នូលទាំងបី ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

### ១- មុខងារនីតិកម្ម

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - គណៈកម្មាធិការអចិន្ត្រៃយ៍បើកកិច្ចប្រជុំចំនួន ០២លើក និងបើកសម័យប្រជុំពេញអង្គចំនួន ០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម<br>២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន | - បានធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា ប្រជុំផ្ទៃក្នុងគណៈកម្មការ ប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា និងបានចាត់ចែងតាមនីតិវិធី ឯកសារពាក់ព័ន្ធផ្សេងៗ<br>- បានសហការរៀបចំជូនសមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ចូលធ្វើសច្ចាប្រណិធានចំនួន០១រូប<br>- បានថតចម្លងឯកសារចំនួន២,១៣៥ច្បាប់ និងបានចងក្រងជាសៀវភៅចំនួន០៨ក្បាល អស់ក្រដាសចំនួន៦០,៨៧៤សន្លឹក<br>- បានសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន០៦លើក មានអ្នកចូលរួមចំនួន២៨៧នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ស្តីពី ការជៀសវាងការយកពន្ធត្រួតគ្នា និងបង្ការការកិបកេងបន្ទុំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល<br>៣- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ ស្តីពី ការកំណត់ច្រកទ្វារព្រំដែនឆ្លងកាត់នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពី កិច្ចសម្របសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់<br>៤- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ាន ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>៥- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពី ការបង្កើតសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ។ | ផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍មកពីខាងក្រៅស្ថាប័នចំនួន២២១នាក់ ស្មើនឹង១១លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៣លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន១៦លើក ស្មើនឹង១៦នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់ពីរាជរដ្ឋាភិបាល និងរដ្ឋសភា ហើយបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន២៩៣ច្បាប់ ហើយបានចាត់ចែងតាមនីតិវិធី<br>- បានផ្ញើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់<br>- បានបញ្ចូលព្រះរាជក្រម ព្រះរាជក្រឹត្យ និងអនុក្រឹត្យចំនួន១០៨ប្រធានបទ ទៅក្នុងវេបសាយច្បាប់ (Laws.gov.kh)<br>- បាន Upload និងថតរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការទាំង១០ និងតាមភូមិភាគចំនួន៧៥ប្រធានបទ បញ្ចូលទៅក្នុងវេបសាយព្រឹទ្ធសភា Senate.gov.kh និង Senate news<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៦លើក និងប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន៥២លើក |

| | |
|---|---|
| | - បានផ្សព្វផ្សាយសកម្មភាពគណៈកម្មការទាំង១០ ព្រឹទ្ធសភា តាមប្រព័ន្ធ YouTube ចំនួន០៤លើក និងតាមបណ្តាញសង្គម Facebook ចំនួន២៣លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន២១លើក។ |

## ២- មុខងារតំណាង

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញចូលរួមជាកិត្តិយស និងដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីប្រទាន និងពន្លត់ភ្លើងជ័យ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ នៅវិមានឯករាជ្យ<br>+ អញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាអុំទូក មុខព្រះបរមរាជវាំង ព្រមទាំងពិសា | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន អញ្ជើញជាគណៈ-អធិបតីក្នុងពិធីផ្លូវការនានា និងកិច្ចប្រជុំផ្សេងៗសរុបចំនួន២២១លើក<br>- បានរៀបចំពិធីពិសាអាហារថ្ងៃត្រង់សាមគ្គី និងអកអំបុកខ្មែរថៃជាតិ សាសនា ព្រះមហាក្សត្រ ៩វិច្ឆិកា ជូនបងប្អូនកម្មករ កម្មការិនី និងមន្ត្រីរាជការចំនួន៧០០នាក់ ក្នុងឱកាសពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៣លើក<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៤ច្បាប់ ស្មើនឹង១០៦នាក់<br>- បានថតចម្លងឯកសារចំនួន៦១៨ច្បាប់ អស់ក្រដាសចំនួន២,៥៩០សន្លឹក<br>- បានផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងភេសជ្ជៈ សម្រាប់ពិធីផ្សេងៗចំនួន០២លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះ |

| | |
|---|---|
| អាហារថ្ងៃត្រង់សាមគ្គីជាមួយបងប្អូនកម្មករ កម្មការិនី មន្ត្រីរាជការ និងទទួលទាន អំបុកខ្មែរថៃជាតិ សាសនា ព្រះមហាក្សត្រ<br>+ អញ្ជើញចុះជួបសំណេះសំណាលជាមួយ មន្ត្រីរាជការ និងក្រុមយុវជនសហភាព-សហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) នៅរាជធានីភ្នំពេញ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធ និងពិធីបូជាព្រះសព **សម្តេចព្រះរាជបុត្រី ព្រះរៀម នរោត្តម បុប្ផាទេវី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ អតីតសមាជិកព្រឹទ្ធសភា និងជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណា ព្រះបាទសម្តេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងព្រះសពសម្តេចធម្មលិខិតកត្តិបណ្ឌិត **លាស់ ឡាយ** សម្តេចព្រះសង្ឃនាយករងទី១ និងជាព្រះចៅអធិការវត្តសន្សំកុសល<br>+ អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា ព្រឹទ្ធសភា ស្តីពី ការពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញា បំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញា បំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គម- | បំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៣៧លើក ស្មើនឹង១៤៧នាក់<br>- បានទទួលលិខិតចូលចំនួន៥១៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៥៥ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៦៧លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ក្នុងពិធីផ្សេងៗចំនួន០៤លើក ស្មើនឹង៣១នាក់<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបភាពស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញសង្គមព្រឹទ្ធសភាចំនួន៥៣លើក<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៧០នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៤៨ក្បាល និងសងវិញចំនួន៣៧ក្បាល<br>- បានផលិតទស្សនាវដ្តីប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩ ចំនួន២,៥០០ក្បាល<br>- បានផលិតវីដេអូ ស្តីពី ជំនួបសវនាការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន០៥លើក កិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំឆមាសឆ្នាំ២០១៩ និងពិធីបិទវគ្គបណ្តុះបណ្តាលរបស់អគ្គលេខាធិការព្រឹទ្ធសភា និងព័ត៌មានព្រឹទ្ធសភាចំនួន០៧លើក |

| | |
|---|---|
| និយមវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញចូលរួមប្រជុំថ្លែងឯកសារប្រវត្តិសាស្ត្រទំនាក់ទំនងកម្ពុជា និងវៀតណាម (ឆ្នាំ១៩៣០-២០១០) ដែលបានកែសម្រួលរួចភាគទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ី-ប៉ាស៊ីហ្វិច ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានអញ្ជើញថ្លែងបិទអន្តរាគមន៍ក្នុងកិច្ចពិភាក្សាគន្លឹះ ក្រោមប្រធានបទស្តីពី តួនាទីរបស់រដ្ឋាភិបាល ស្ថាប័នសភា និងសង្គមស៊ីវិល ក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗនាពេលបច្ចុប្បន្ន ព្រមទាំងអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជូនគណៈប្រតិភូអន្តរជាតិដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ី-ប៉ាស៊ីហ្វិច<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល។<br>- បានផ្ញើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូនមន្ត្រីនគរបាល | - បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន២៨លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០២លើក របស់មន្ត្រីនគរបាលយុត្តិធម៌ជំនាន់២៤ មកពីកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងនិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុបចំនួន១៥៥នាក់។ |

| | |
|---|---|
| យុត្តិធម៌ជំនាន់២៤ មកពីកងរាជអាវុធហត្ថលើផ្ទៃប្រទេសចំនួន១០៥នាក់<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៨ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៨ករណី កំពុងពិនិត្យសិក្សាចំនួន ០៣ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន០១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ទូទាំងប្រទេសចំនួន៧៩លើក ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺ ជូនប្រជា-ពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោល-នយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងសរុបចំនួន១២៥លើក។ | |

## ៣- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យអនុប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃសហភាពអឺរ៉ុប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពតែងតាំងថ្មីនៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ចូលជួបសវនាការ និងសម្តែងការគួរសម<br>- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យក្រុមលេខាធិការដ្ឋានអាស៊ី-ប៉ាស៊ីហ្វិចចូលជួបដើម្បីធ្វើសេចក្តីរាយការណ៍អំពីដំណើរការរៀបចំកិច្ចប្រជុំកំពូលអាស៊ី-ប៉ាស៊ីហ្វិច ព្រមទាំងបានអញ្ជើញជាកិត្តិយសបំពាក់គ្រឿងឥស្សរិយយសសហមេត្រីថ្នាក់មហាសេរីវឌ្ឍន៍ ជូនគណៈទាក់ទងបរទេសមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ក្នុងឱកាសខួបលើកទី៧០ឆ្នាំ នៃថ្ងៃបង្កើតគណៈទាក់ទងបរទេសមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ដើម្បីជាសក្ខីភាពក្នុងការរួមចំណែកពង្រឹងពង្រីកចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងយូរអង្វែងរវាងកម្ពុជា-វៀតណាម និងបានចូលជួបសម្តែងការគួរសម និងពិសាអាហារសាមគ្គីជាមួយសមាជិកការិយាល័យនយោបាយ និងប្រចាំការគណៈកម្មការលេខាមជ្ឈិមបក្សកុម្មុយនីស្ត | - បានរៀបចំទីកន្លែងជូនថ្នាក់ដឹកនាំព្រឹទ្ធសភាក្នុងជំនួបសវនាការ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន០៥លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបជាមួយភ្ញៀវជាតិ និងអន្តរជាតិ ដែលមកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន០៦លើក<br>- បានថតចម្លងឯកសារចំនួន១,៦១៩ច្បាប់ អស់ក្រដាសចំនួន៣៤,៥៨៦សន្លឹក<br>- បានរៀបចំសម្អាត តុបតែងលម្អសាល ផ្គត់ផ្គង់សម្ភារប្រើប្រាស់ និងបម្រើសេវាកេសជ្ជៈ ក្នុងកិច្ចប្រជុំចំនួន១២លើក មានអ្នកចូលរួមចំនួន៧១២នាក់<br>- បានធ្វើកំណត់បង្ហាញ កំណត់ទូត របាយការណ៍ លិខិតឆ្លើយតប ជំនួយស្មារតី និងលិខិតផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគណៈប្រតិភូនានារបស់ព្រឹទ្ធសភាចំនួន១៩លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩នាក់ ស្មើនឹង០៧ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៩លើក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ |

| | |
|---|---|
| វៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាម<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា នៅប្រទេសអូស្ត្រាលី និងទៅបំពេញទស្សនកិច្ចឈ្វេងយល់ និងផ្លាស់ប្តូរបទពិសោធន៍អំពីតួនាទី និងភារកិច្ចរបស់សភា នៅសាធារណរដ្ឋបារាំង ព្រមទាំងអញ្ជើញទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ របស់សភាតំបន់អាស៊ី (APA) នៅសាធារណរដ្ឋតួកគី។ | នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៣៥លើក ស្មើនឹង៦៦នាក់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១២លើក ស្មើនឹង២៥នាក់<br>- បានរៀបចំបែបបទជូនសមាជិក សមាជិកាព្រឹទ្ធសភាអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា នៅសាធារណ-រដ្ឋបារាំង និងប្រទេសអូស្ត្រាលីចំនួន០២លើក<br>- បានរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា និងចូលរួមសន្និបាត សិក្ខាសាលា វេទិកា នៅសាធារណរដ្ឋបារាំង និងប្រទេសហ្វីលីពីនចំនួន០៤លើក<br>- បានទំនាក់ទំនងជាមួយបណ្ណាល័យនៃសាកល-វិទ្យាល័យអាស៊ី-អឺរ៉ុប ស្តីពី ការបន្តចុះអនុស្សរណៈយោគយល់ MOU រវាងបណ្ណាល័យព្រឹទ្ធសភា និងបណ្ណាល័យអាស៊ី-អឺរ៉ុប។ |

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | - បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៥៥ច្បាប់<br>- បានពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (ឆ្នាំ២០២០-២០៣០) និងទស្សនវិស័យនៃដំណើរការទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២០-២០៣០)<br>- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ |

ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧០ច្បាប់។

- **ការងារគ្រប់គ្រងបុគ្គលិក៖**

+ បានប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការពិនិត្យ និងវាយតម្លៃបេក្ខជនត្រៀមតាំងស៊ប់ក្នុងមុខតំណែងគ្រប់គ្រងក្នុងអង្គការលេខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩នាក់
+ ប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
+ បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន១៩៥ច្បាប់
+ បានទទួលលិខិតសុំច្បាប់របស់មន្ត្រីរាជការ និងកត់ត្រាចូលសៀវភៅការងារនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០៦ច្បាប់
+ បានរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ។

- **ការងារបណ្តុះបណ្តាលធនធានមនុស្ស៖**

+ បានរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលបឋមសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌថ្មីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
+ បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន០៥នាក់ សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៤លើក មានសិក្ខាកាមចូលរួមចំនួន១២៧នាក់។

- **ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖**

+ បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច

| | |
|---|---|
| | និងហិរញ្ញវត្ថុ<br>+ បានប្រជុំបែងចែកថវិកាឆ្នាំ២០២០ របស់ព្រឹទ្ធសភា ជូនរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល<br>+ បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តឆ្នាំ២០២០ ជាមួយអង្គភាពថវិកា<br>+ បានរៀបចំតភ្ជាប់បណ្តាញប្រព័ន្ធ (FMIS) និងការប្រើប្រាស់<br>+ បានរៀបចំរបាយការណ៍ស្តីពី ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>+ បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលាផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០១សំណើ<br>+ បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ០៧លើក មានអ្នកចូលរួមចំនួន៣១៨នាក់<br>+ បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២១៦លើក<br>+ បានថតចម្លងឯកសារចំនួន២,៨៧៧ច្បាប់ |

| | |
| --- | --- |
| | ចងក្រងធ្វើជាសៀវភៅចំនួន៩៤ក្បាល អស់ក្រដាសចំនួន៣៨,៧១០សន្លឹក ព្រមទាំងបានជួសជុលសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៥លើក<br>+ បានផ្ដល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញចំនួន ៨៦លើក ស្មើនឹង១០៣នាក់<br>+ បានជួសជុលរថយន្ត ព្រមទាំងទិញសម្ភារៈផ្សេងៗ សម្រាប់បំពាក់រថយន្តចំនួន១៣លើក។<br>- **ការកសាង អភិវឌ្ឍន៍ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ៖**<br>+ រៀបចំស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤<br>+ បានសាងសង់រោងដែកប្រក់ដំបូលការបូណាត នៅខាងមុខសាលសិក្ខាសាលាខាងត្បូង និងបាំងជញ្ជាំង Smart Board ក្រោមដំបូលអក្សរ W នៅខាងមុខបណ្ណាល័យ<br>+ បានប្ដូរពិដាន និងជួសជុលកែលម្អអគារនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស អង្គភាពសន្តិសុខ និងអគារដាក់ SERVER ខាងមុខអគារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ បន្តជួសជុលបណ្ដាញអគ្គិសនី បណ្ដាញទឹក ម៉ាស៊ីនត្រជាក់ ទ្វារចេញ-ចូល នៅសាលប្រជុំពេញអង្គ អគារក្រហម អគារ DEF អគារជប៉ុន និងសាលពិសេសធំ<br>+ បានកែលម្អសួនច្បារ និងបានរៀបចំដាំដើមឈើថ្មីក្នុងបរិវេណព្រឹទ្ធសភាចំនួន០១លើក ស្មើនឹង |

| | |
|---|---|
| | ០៣បួង<br>+ ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិក គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៩១គ្រឿង/លើក<br>+ បានសហការជាមួយក្រុមហ៊ុន Maintenances ត្រួតពិនិត្យជណ្តើរយន្តចំនួន០២លើក<br>+ សហការជាមួយក្រុមហ៊ុនកម្ចាត់សត្វកណ្តៀរ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៤០លើក<br>+ បានបង្កើត Email, Telegram ជាមធ្យោបាយសម្រាប់ទទួល និងបញ្ជូនឯកសារ ជូនសមាជិកសមាជិកាព្រឹទ្ធសភា<br>+ បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៧៧គ្រឿង និងបាន Upload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៨០ប្រធានបទ។<br>- ការងារផ្សេងៗ៖<br>+ បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព និងធ្វើហ្វុងអក្សរ ចងទង់ជាតិ ចងបដា ពាក្យស្លោកចំនួន០៧លើក<br>+ បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិត |

| | |
|---|---|
| | ខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ៧៥ប្រធានបទ<br>+ បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៦លើក<br>+ បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងរាជកិច្ចចំនួន១៦២ក្បាល ព្រមទាំងបានបោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ អ៊ុតក្របសៀវភៅ និងបញ្ចូលសៀវភៅកាសាអង់គ្លេសក្នុងកម្មវិធី KOHA ចំនួន២៦២ក្បាល<br>+ បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន ៥៧ក្បាល។ |

## II-ទិសដៅការងារសម្រាប់ខែធ្នូ ឆ្នាំ២០១៩

### ១- មុខងារនីតិកម្ម

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពី សហជីព

២-កិច្ចព្រមព្រៀងស្តីពី ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ

៣-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

៤- សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

### ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជួបសវនាការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

### ៣- មុខងារតំណាង

-ត្រៀមរៀបចំកម្មវិធីជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងចូលរួមក្នុងពិធីផ្លូវការនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមសហការរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបសវនាការ សម្ភែងការគួរសម និងជួបសំណេះសំណាលជាមួយឥស្សរជនជាន់ខ្ពស់ជាតិ និងអន្តរជាតិ

-ត្រៀមរៀបចំសិក្ខាសាលា និងពិធីសំណេះសំណាលផ្សេងៗ

-ត្រៀមរៀបចំវេទិកានៅខេត្តកំពត និងខេត្តមណ្ឌលគិរី

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ/អន្តរជាតិ និងអង្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមចូលរួមជាមួយរដ្ឋសភា ដើម្បីរៀបចំ ASEP/ASEM ឆ្នាំ២០២០

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-បន្តការងារតាមដាន៖ ការស្នើសុំគោលការណ៍ស្តីពី របបសន្តិសុខសង្គម (ប.ស.ស) និងរថយន្ត ០១គ្រឿងចុងក្រោយ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា

-បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងបរិវេណព្រឹទ្ធសភា

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលរួមអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត (ឆ្នាំ២០២០)

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមធ្វើដំណើរសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតម្រូវការជាក់ស្តែង

-ត្រៀមលក្ខណៈចូលរួមពិធីបុណ្យសំខាន់ៗនានារួមមានៈ ទិវាសិទ្ធិមនុស្សអន្តរជាតិ និងពិធីបុណ្យជាតិផ្សេងៗទៀត

-ត្រៀមបោះពុម្ពដំណាច់ឆ្នាំៈ ប័ណ្ណជូនពរ ទិនានុលេខន៍ ប្រតិទិន និងប័ណ្ណរថយន្ត

-ត្រៀមបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

-ត្រៀមការងារបុគ្គលិកឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារបណ្តុះបណ្តាលឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមការងារលទ្ធកម្មឆ្នាំ២០១៩ និងផែនការឆ្នាំ២០២០

-ត្រៀមរៀបចំបែងចែកកញ្ចប់ថវិកាឆ្នាំ២០២០សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ត្រៀមរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៩

-ត្រៀមរបាយការណ៍បែងចែក និងប្រើប្រាស់ថវិកាឆ្នាំ២០២០

-បន្តសហការជាមួយក្រុមការងារ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធFMIS

-ត្រៀមបន្តប្រជុំពិនិត្យក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (ឆ្នាំ២០២០-២០៣០)

-ត្រៀមរៀបចំថវិកាតាមកម្មវិធីរួម និងតាមអង្គភាពថវិកាឆ្នាំ២០២០ៗ

**III-សេចក្តីសន្និដ្ឋាន**

ក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកក្នុងការបម្រើសេវាជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាលើសេវាទ្រទ្រង់មុខងារនីតិកម្ម ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក បានយ៉ាងល្អប្រសើរ។ ចំពោះមុខងារតំណាង បានអមដំណើរសមាជិកព្រឹទ្ធសភាចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ទន្ទឹមនឹងនេះ ការអភិវឌ្ឍស្ថាប័ន ពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងអស់ឱ្យក្លាយជាអ្នកពូកែពហុវិស័យទាំងចំណេះដឹង ជំនាញឯកទេស ជំនាញបច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាព

ភាសាបរទេស។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបានពង្រឹងពង្រីក និងលើកកម្ពស់តាមរយៈការចូលរួមប្រជុំមហាសន្និបាត និងទស្សនកិច្ចសិក្សា ព្រមទាំងការស្វែងរកជំនួយពីប្រភពខាងក្រៅបន្ថែមទៀត។

ការចូលរួមថែទាំឱ្យបានល្អនូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងបរិស្ថានធម្មជាតិឱ្យបានល្អប្រសើរ ដូចជាប្រព័ន្ធទឹក អគ្គិសនី ថ្នល់ លូ បង្គូរទឹក សួនច្បារ និងប្រព័ន្ធចរាចរណ៍ គឺជាកាតព្វកិច្ចរួម។ សំរាម និងថង់ប្លាស្ទិក រួមទាំងបញ្ហាចំណតរថយន្ត គឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បន្ថែមទន្ទឹមនឹងវិតបន្តឹងការគោរពវិន័យ និងសន្តិសុខសុវត្ថិភាព។៚

ថ្ងៃចន្ទ ១៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩

**អគ្គលេខាធិការ**

**អ៊ុំ_សារឹទ្ធ**